[Insert School District Letterhead]

សូមជូនចំពោះមាតាបិតា/អ្នកអាណាព្យាបាល ៖

សាលារៀនរបស់យើង មានផ្តល់អាហារមានសុខភាពល្អរៀងរាល់ថ្ងៃ ។ អាហារពេលព្រឹកថ្លៃ [$]; អាហារថ្ងៃត្រង់ថ្លៃ [$]។

កូនរបស់អ្នក អាចមានគុណសម្បត្តិទទួលអាហារដោយ ឥតគិតថ្លៃ ឬអាហារដោយបញ្ចុះថ្លៃ ។ ដោយបញ្ចុះថ្លៃគឺ [$] សំរាប់អាហារថ្ងៃត្រង់ ។ អាហារពេលព្រឹក "ដោយបញ្ចុះថ្លៃ" គឺបានផ្តល់ឲ្យដោយឥតគិតថ្លៃ ។ ដើម្បីដាក់ពាក្យសុំម្ហូបអាហារនៅសាលាដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ សូមបំពេញលិខិតដាក់ពាក្យសុំអត្ថប្រយោជន៍(ជំនួយ)ការអប់រំ ដែលបានដាក់ភ្ជាប់មកជាមួយ ដោយធ្វើតាមសេចក្តីណែនាំទាំងឡាយនៅទំព័រម្ខាងទៀត ។ ការនេះវាក៏នឹងជួយសាលារៀនរបស់យើង ឲ្យមានគុណសម្បត្តិទទួលថវិកា និងការចុះថ្លៃថែមទៀតផងដែរ ។

សូមផ្ញើលិខិតដាក់ពាក្យសុំអត្ថប្រយោជន៍ការអប់រំ ដែលបានបំពេញចប់សព្វគ្រប់ ត្រឡប់ទៅ ៖

**1. តើអ្នកណាអាចទទួលអាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃបាន?** ក្មេងៗនៅក្នុងក្រុមគ្រួសារដែលទទួលអាហាររូបិយប័ណ្ណ (Food Stamps), គំរោងការវិនិយោគទុនគ្រួសាររដ្ឋមីនេសូតា (Minnesota Family Investment Plan - MFIP), ឬកម្មវិធីការចែកចាយម្ហូបអាហារ នៅក្នុងដីបំរុងទុកសំរាប់ជនជាតិដើមឥណ្ឌៀន (Food Distribution Program on Indian Reservations - FDPIR) ហើយនិងភាគច្រើននៃកូនចិញ្ចឹម អាចទទួលអាហារដោយ ឥតគិតថ្លៃបាន ដោយមិនចាំបាច់រាយការណ៍ប្រាក់ចំណូលពីសមាជិកគ្រួសារ។ កូនក្មេងក៏អាចទទួលអាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃបានដែរ បើប្រាក់ចំណូលក្នុងក្រុមគ្រួសារ ស្ថិតនៅក្នុងចំនួនដែលបានបង្ហាញ សំរាប់ទំហំក្រុមគ្រួសាររបស់អ្នក នៅលើតារាងក្នុងទំព័របន្ទាប់ ។ ការដាក់ពាក្យសុំអត្ថប្រយោជន៍ការអប់រំ មិនអាចបានផ្តល់ឲ្យឡើយ បើព័ត៌មានដែលបានជំរូវមិនបានផ្តល់ឲ្យទេនោះ ។

**2. ខ្ញុំមានទទួល WIC ។ តើកូនរបស់ខ្ញុំ អាចទទួលអាហារដោយ ឥតគិតថ្លៃបានឬទេ?** ក្មេងៗនៅក្នុងក្រុមគ្រួសារដែលទទួល WIC *អាចនឹង*មានសិទ្ធិទទួលអាហារ ដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃបាន ។ សូមបំពេញលិខិតដាក់ពាក្យសុំអត្ថប្រយោជន៍ការអប់រំ ។

**3. តើខ្ញុំគួរតែបំពេញលិខិតដាក់ពាក្យសុំឬទេ បើខ្ញុំបានទទួលសំបុត្រមួយច្បាប់ពីសាលារៀននៅឆ្នាំនេះ ថាកូនរបស់ខ្ញុំត្រូវគេបញ្ជាក់ថាបាន ទទួលអាហារដោយឥតគិតថ្លៃ ឬ ដោយបញ្ចុះថ្លៃ ដែលយោងទៅតាមទិន្នន័យពីក្រសួងបំរើមនុស្សនៃរដ្ឋមីនីសូតា?** ចូរកុំបំពេញលិខិតដាក់ពាក្យសុំ ចំពោះក្មេងៗដែលបានយល់ព្រមរួចហើយ សំរាប់អាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ ។ ប្រសិនបើអ្នកមានកូនខ្លះក្នុងចំណោម កូនទាំងអស់ មិនបានគេបញ្ជាក់ថាបានទេនោះ អ្នកអាចបំពេញលិខិតដាក់ពាក្យសុំ ចំពោះកូនណាដែលមិនអាចទទួលបាន ។

**4. តើគេនឹងពិនិត្យមើលព័ត៌មានដែលខ្ញុំបានផ្តល់ឬទេ?** បាទ/ចាស យើងអាចនឹងស្នើឲ្យអ្នកផ្ញើក្រដាសស្នាមជាភស្តុតាង ។

**5. ចុះបើខ្ញុំគ្មានគុណសម្បត្តិទទួលនៅពេលឥឡូវនេះ តើខ្ញុំអាចដាក់ពាក្យសុំនៅពេលក្រោយទៀតបានឬទេ?** បាទ/ចាស ។ អ្នកអាចដាក់ពាក្យសុំនៅពេលណាមួយ ក្នុងកំឡុងឆ្នាំសិក្សា បើប្រាក់ចំណូលរបស់អ្នកចុះថយ ទំហំក្រុមគ្រួសាររបស់អ្នកមានគ្នាច្រើនឡើង ឬបើអ្នកចាប់ផ្តើមទទួលអាហាររូបយប័ណ្ណ ឬ MFIP ឬ អត្ថប្រយោជន៍ FDPIR ។

**6. ចុះបើខ្ញុំមិនយលស្របជាមួយនឹងការសំរេចរបស់សាលារៀន អំពីការដាក់ពាក្យសុំរបស់ខ្ញុំ?** អ្នកគួរតែពិគ្រោះជាមួយអ្នកមុខអ្នកការនៃសាលារៀន ។ អ្នកក៏អាចស្នើសុំឲ្យមានសវនាការ(ដំណើរស្តាប់រឿងហេតុ)បានដែរ ។

**7. បើអ្នកណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំ មិនមែនជាសញ្ជាតិរដ្ឋអាមេរិកាំង តើខ្ញុំអាចដាក់ពាក្យសុំបានឬទេ?** បាទ/ចាស ។ រូបអ្នក ឬកូនរបស់អ្នក មិនចាំបាច់ជាសញ្ជាតិអាមេរិកាំង ទើបកូនរបស់អ្នកមានគុណសម្បត្តិទទួលអាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ នោះទេ ។

**8. តើខ្ញុំគួរបញ្ចូលអ្នកណាខ្លះ ថាជាសមាជិកនៃក្រុមគ្រួសាររបស់ខ្ញុំ?** អ្នកត្រូវតែបញ្ចូលខ្លួនអ្នក និងមនុស្សផ្សេងៗទៀតទាំងអស់ ដែលកំពុងរស់នៅក្នុងផ្ទះរបស់អ្នក ជាសាច់ញាតិ ឬមិនមែនជាសាច់ញាតិ (ដូចជាតាយាយ ញាតិសន្តានផ្សេង ៗទៀត ឬមិត្តភ័ក្ក ។ ត្រូវបញ្ចូលសមាជិកក្រុមគ្រួសារដែលចេញទៅឆ្ងាយជាបណ្តោះអាសន្ន ដូចជានិស្សិតមហាវិទ្យាល័យ ជាដើម ។

**9. ចុះបើសិនជាប្រាក់ចំណូលរបស់ខ្ញុំតែងតែផ្លាស់ប្តូរជានិច្ច?** ត្រូវកត់ចំនួនជាធម្មតាដែលអ្នកទទួល ។ បើតាមធម្មតា អ្នកទទួលប្រាក់ធ្វើការលើសម៉ោង នោះក៏គិតបញ្ចូលវាដែរ ក៏ប៉ុន្តែបើអ្នកទទួលវាតែម្តងម្កាល មិនបាច់គិតបញ្ចូលវាទេ ។

**10. តើព័ត៌មានដែលខ្ញុំផ្តល់ នឹងបានរក្សាទុកដោយរបៀបណា?** ព័ត៌មានដែលអ្នកផ្តល់ នៅលើក្រដាសដាក់ពាក្យសុំ និង ការយល់ព្រម សំរាប់អត្ថប្រយោជន៍ ម្ហូបសាលា នឹងបានការពារទុក ជាទិន្នន័យឯកជន ។

11.តើអ្នកត្រូវការប្រាប់អ្នកធ្វើការសាលា ប្រសិនបើប្រាក់ចំណូលរបស់ខ្ញុំឡើង ឬចំនួនក្រុមគ្រួសារថយចុះ បន្ទាប់ពីខ្ញុំមានគេយល់ព្រមអោយ អាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ? ទេ ការយល់ព្រមសំរាប់ អាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃនោះ វាល្អសំរាប់តែមួយឆ្នាំ។

បើសិនជាអ្នកមានសំណួរអ្វីផ្សេងទៀត ឬបើត្រូវការជំនួយ សូមហៅទៅ [phone number]។

ដោយនូវក្តីស្មោះស្ម័គ្រ

[signature]

# សេចក្តីណែនាំ សំរាប់ការបំពេញ
# លិខិតដាក់ពាក្យសុំ អត្ថប្រយោជន៍ការអប់រំ

**បើក្រុមគ្រួសាររបស់អ្នក ទទួលអាហាររូបិប័ណ្ណ, MFIP, ឬ FDPIR ត្រូវធ្វើតាមសេចក្តីណែនាំទាំងឡាយនៅខាងក្រោម :**

**ផ្នែកទី 1 :** គូសប្រអប់នេះ បើនេះគឺជាការបំពេញដាក់ពាក្យសុំអាហារនៅសាលារៀនជាលើកដំបូង សំរាប់ក្មេងណាម្នាក់ ។

**ផ្នែកទី 2 :** គូសប្រអប់ដែលសរសេរថា "កូនក្មេងទាំងអស់ នៅក្នុងក្រុមគ្រួសារ"។ កត់ឈ្មោះ ខែថ្ងៃឆ្នាំកំណើត ចំណាត់ថ្នាក់ សាលារៀន និងលេខ សំណុំរឿង របស់ក្មេងនិមួយៗ ។ លេខសំណុំរឿងជំនួយពេទ្យ (Medical Assistance) *ពុំ*មានគុណសម្បត្តិទទួលទេ ។

**ផ្នែកទី 3 :** រំលងផ្នែកនេះ ។

**ផ្នែកទី 4 :** សមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ ត្រូវតែចុះហត្ថលេខាលើលិខិតបំពេញ ។ លេខសូស្យាល់សឺគ្យួរិទី គឺមិនចាំបាច់ទេ ។

**បើអ្នកកំពុងតែដាក់ពាក្យសុំ សំរាប់កូនចិញ្ចឹម ត្រូវធ្វើតាមសេចក្តីណែនាំទាំងឡាយនៅខាងក្រោម :**

**ត្រូវប្រើលិខិតដាក់ពាក្យផ្សេងទៀត សំរាប់កូនចិញ្ចឹមនិមួយៗ ។**

**ផ្នែកទី 1 :** គូសប្រអប់នេះ បើនេះគឺជាការបំពេញដាក់ពាក្យសុំអាហារនៅសាលាជាលើកដំបូង សំរាប់ក្មេងនេះ ។

**ផ្នែកទី 2 :** គូសប្រអប់ដែលសរសេរថា "កូនចិញ្ចឹមម្នាក់"។ កត់ឈ្មោះ ខែថ្ងៃឆ្នាំកំណើត ចំណាត់ថ្នាក់ និងសាលារៀន របស់កូនចិញ្ចឹម ។ នៅក្នុងជួរខាងស្តាំបំផុតនៃ "ប្រាក់ SSI ឬប្រាក់ចំណូលធម្មតាផ្សេងៗទៀតសំរាប់ក្មេង" ត្រូវកត់ប្រាក់ចំណូលអ្វីមួយដែលបានតែងតាំងសំរាប់ការចាយវាយផ្ទាល់ខ្លួនរបស់ក្មេង ឬសរសេរថា(គ្មានទេ) "none" បើក្មេងនោះគ្មានប្រាក់ចំណូលសំរាប់ចាយវាយផ្ទាល់ខ្លួនទេ ។

**ផ្នែកទី 3 :** រំលងផ្នែកនេះ ។

**ផ្នែកទី 4 :** សមាជិកក្រុមគួសារជាមនុស្សពេញវ័យ ត្រូវតែចុះហត្ថលេខាលើលិខិតបំពេញ ។ លេខសូស្យាល់សឺគ្យួរិទី គឺមិនចាំបាច់ទេ ។

**ក្រុមគ្រួសារផ្សេងៗទៀតទាំងអស់ រួមទាំងក្រុមគ្រួសារដែលទទួល WIC ត្រូវធ្វើតាមសេចក្តីណែនាំទាំងឡាយនៅខាងក្រោម :**

បំពេញលិខិតដាក់ពាក្យសុំអត្ថប្រយោជន៍ការអប់រំ បើប្រាក់ចំណូលនៃក្រុមគ្រួសាររបស់អ្នក មានតិចជាង ឬស្មើនឹងចំនួន ដែលបានបង្ហាញ សំរាប់ទំហំក្រុមគ្រួសាររបស់អ្នក នៅក្នុងតារាងនេះ ។
ចំនួនប្រាក់ចំណូលទាំងនេះ មានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃទី១ ខែកក្កដា ឆ្នាំ 2010 ទៅទល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ 2011។

ប្រាក់ចំណូលសរុបនៃក្រុមគ្រួសារ - អតិបរិមា

| ទំហំក្រុមគ្រួសារ | $<br>ក្នុងមួយឆ្នាំ | $<br>ក្នុងមួយខែ | $<br>ពីរដង ក្នុងមួយខែ | $<br>ក្នុង 2 អាទិត្យ | $<br>ក្នុងមួយអាទិត្យ |
|---|---|---|---|---|---|
| 1 | 20,036 | 1,670 | 835 | 771 | 386 |
| 2 | 26,955 | 2,247 | 1,124 | 1,037 | 519 |
| 3 | 33,874 | 2,823 | 1,412 | 1,303 | 652 |
| 4 | 40,793 | 3,400 | 1,700 | 1,569 | 785 |
| 5 | 47,712 | 3,976 | 1,988 | 1,836 | 918 |
| 6 | 54,631 | 4,553 | 2,277 | 2,102 | 1,051 |
| 7 | 61,550 | 5,130 | 2,565 | 2,368 | 1,184 |
| 8 | 68,469 | 5,706 | 2,853 | 2,634 | 1,317 |
| បូកបន្ថែមសមាជិក ក្រុមគ្រួសារនិមួយៗ | 6,919 | 577 | 289 | 267 | 134 |

**ផ្នែកទី 1 :** គូសប្រអប់នេះ បើនេះគឺជាការបំពេញដាក់ពាក្យសុំអាហារនៅសាលាជាលើកដំបូង សំរាប់ក្មេងណាម្នាក់ ។

**ផ្នែកទី 2 :** គូសប្រអប់សរសេរថា "កូនក្មេងទាំងអស់ នៅក្នុងក្រុមគ្រួសារ។ កត់ឈ្មោះ ខែថ្ងៃឆ្នាំកំណើត ចំណាត់ថ្នាក់ និងសាលារៀនរបស់ក្មេង ។ បើក្មេងទទួលប្រាក់ចំណូលជាធម្មតា ដូចជាប្រាក់ SSI ឬប្រាក់រកបានពីការងារ។ ត្រូវកត់ចំនួន និងភាពញឹកញាប់ដែលបានទទួល នៅក្នុងជួរខាងស្តាំបំផុត ។ សូមកុំសរសេរនូវប្រាក់រកបាន ម្តងម្កាលអោយសោះ ដូចជា ការមើលកូនអោយគេ។

**ផ្នែកទី 3 :** ត្រូវរាយការណ៍ប្រាក់ចំណូលទាំងអស់ សំរាប់សមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យទាំងអស់ ។

**ឈ្មោះ** - ត្រូវកត់នាមខ្លួន និងនាមត្រកូល នៃមនុស្សពេញវ័យនិមួយៗដែលកំពុងរស់នៅក្នុងផ្ទះរបស់អ្នក ជាសាច់ញាតិ ឬមិនមែនជាសាច់ញាតិ (ដូចជាតាយាយ ញាតិសន្តានផ្សេងៗ ទៀត ឬមិត្រភ័ក្តិ) រួមទាំងខ្លួនអ្នក ។ ត្រូវបញ្ចូលសមាជិកក្រុមគ្រួសារដែលចេញទៅឆ្ងាយជាបណ្តោះអាសន្ន ដូចជានិស្សិតមហាវិទ្យាល័យ ជាដើម ។ ដាក់ភ្ជាប់សន្លឹកទំព័រមួយទៀត បើសិនជាចាំបាច់ ។

**គ្មានប្រាក់ចំណូលទេ :** គូសនៅលើប្រអប់នេះ ប្រសិនបើមនុស្សម្នាក់គ្មានប្រាក់ចំណូលទេនោះ។

**ប្រាក់ថ្លៃឈ្នួលធ្វើការ និងប្រាក់ខែរួមមុនកាត់ពន្ធជាប្រចាំខែ :** នៅក្បែរ**ប្រាក់ចំណូលរួមមុនកាត់ពន្ធ** របស់មនុស្សពេញវ័យនិមួយៗ ដែលបានពីធ្វើការមុនកាត់ពន្ធ និងការកាត់ផ្សេងៗទៀតដែលជាប្រាក់*មិន*យកទៅផ្ទះ ។ ត្រូវសរសេរភាពញឹកញាប់ដែលបានទទួលប្រាក់ចំណូល (រាល់អាទិត្យ រាល់ពីរអាទិត្យម្តង ពីរដងមួយខែ ឬជាប្រចាំខែ) នៅក្បែរចំនួននិមួយៗ ។

**ប្រាក់ចំណូលទាំងអស់ផ្សេងៗទៀត :** កត់ **ចំនួនផ្សេងៗទៀតទាំងអស់** ជាបន្ថែមទៅលើប្រាក់ថ្លៃឈ្នួលធ្វើការ និងប្រាក់ខែ ទទួលជាទៀងទាត់ ពីប្រភពណាមួយ។ ត្រូវសរសេរភាពញឹកញាប់ដែលបានទទួលប្រាក់ចំណូល នៅក្បែរចំនួននិមួយៗ ។ សំរាប់អ្នកមានមុខរបរខ្លួនឯង ត្រូវកត់ប្រាក់ចំណូល*ទូទាត់រួច* (បន្ទាប់ពីការចំណាយនៃជំនួញ) នៅទីនេះ ។

**ផ្នែកទី 4 :** ប្រសិនបើកូនរបស់អ្នកត្រូវបានគេយល់ព្រមឱ្យទទួលអាហារ, ពត៌មាននេះត្រូវបានចែកចាយជាយមួយនឹងកម្មវិធីរាប់រងសុខុមាលភាពនៃរដ្ឋមីនីសូតា ដើម្បីរកក្មេងដែលអាចទទួលអត្ថនេះប្រយោជន៍បាន។ ទុកប្រអប់អោយនៅទំនេរ ដើម្បីអនុញ្ញាតអោយចែកចាយពត៌មាន សំរាប់គោលបំណងនេះឯង។

**ផ្នែកទី 5 :** សមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ ត្រូវតែចុះហត្ថលេខាលើលិខិតបំពេញ ទាំងផ្តល់លេខសូស្យាល់សឺគ្យួរិទី របស់គេផង ។ បើមនុស្សដែលចុះហត្ថលេខាលើលិខិតបំពេញពុំមានលេខសូស្យាល់សឺគ្យួរិទីទេ គេអាចបញ្ជាក់ពីការនេះបាន ដោយគូសប្រអប់នេះ ។

# ការដាក់ពាក្យសុំ អត្ថប្រយោជន៍ការអប់រំ

**ម្ហូបអាហារនៅសាលារៀនដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ • សាលា ឆ្នាំ 2010 - 2011 • កម្មវិធីសំរាប់សាលារៀន ដែលបានទទួលថវិកាពីរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ**

**1.** បើសិនជាការដាក់ពាក្យសុំសំម្ហូបអាហារនៅសាលារៀនជាលើកដំបូង សំរាប់ក្មេងណាម្នាក់ដែលបានកត់ឈ្មោះនៅខាងក្រោម សូមគូសប្រអប់នេះ ☐ ។

**2.** គូសប្រអប់មួយ : ☐ **កូនក្មេងទាំងអស់នៅក្នុងក្រុមគ្រួសារ** លើកលែងតែកូនចិញ្ចឹម - ចាប់តាំងពីទើបកើត រហូតដល់ចូលរៀននៅថ្នាក់មធ្យមសិក្សា ។ សូមដាក់ភ្ជាប់ព័ត៌មានបន្ថែម បើសិនជាចាំបាច់ ។

☐ **កូនចិញ្ចឹមម្នាក់** នៅក្នុងការថែរក្សារបស់ខ្ញុំ (ដែលជាការទទួលខុសត្រូវនៃភ្នាក់ងារសង្គមកិច្ច ឬតុលាការ) ។ សូមបំពេញលិខិតដាក់ពាក្យសុំផ្សេងទៀត សំរាប់កូនចិញ្ចឹមនិមួយៗ ។ ចូរកុំបញ្ចូលជាមួយគ្នានូវកូនចិញ្ចឹម និងកូនក្មេងដទៃ នៅលើក្រដាសពាក្យសុំនេះ ។ ត្រូវសរសេរនៅជួរខាងក្រោយបង្អស់នៃថវិកាថែរក្សាកូនចិញ្ចឹម ដែលបញ្ជាក់ច្បាស់លាស់នៃការចាយវាយផ្ទាល់ខ្លួនសំរាប់កូនចិញ្ចឹម ។ បើសិនជាគ្មានថវិកាត្រូវបានតែងតាំងសំរាប់ឲ្យកូនចិញ្ចឹមចាយវាយផ្ទាល់ខ្លួនទេ ត្រូវសរសេរពាក្យ(គ្មានទេ) "none" នៅខាងស្តាំបង្អស់។

| **ឈ្មោះក្មេងទាំងអស់ ក្នុងក្រុមគ្រួសារ** លើកលែងតែកូនចិញ្ចឹម *ឬឈ្មោះកូនចិញ្ចឹម* នាមខ្លួន | នាមត្រកូល | **ខែថ្ងៃឆ្នាំកំណើត** ខែ/ ថ្ងៃ/ ឆ្នាំ | **ថ្នាក់** (មត្តេយ្យ សាលា-ទី 12) | សាលារៀន | បើសិនជាមាន **លេខសំណុំរឿង (MFIP, អាហារូបិប័ណ្ណ, ឬ FDPIR តែប៉ុណ្ណោះ)** | បើសិនជាមាន **ប្រាក់ SSI ឬប្រាក់ចំណូលទៀងទាត់ ផ្សេងទៀត សំរាប់ក្មេង** |
|---|---|---|---|---|---|---|
| 1 | | ____/____/____ | | | | $______ក្នុងមួយ _____ |
| 2 | | ____/____/____ | | | | $______ក្នុងមួយ _____ |
| 3 | | ____/____/____ | | | | $______ក្នុងមួយ _____ |
| 4 | | ____/____/____ | | | | $______ក្នុងមួយ _____ |
| 5 | | ____/____/____ | | | | $______ក្នុងមួយ _____ |

**3.** កត់ឈ្មោះ *មនុស្សពេញវ័យទាំងអស់*ក្នុងក្រុមគ្រួសារ *ប្រាក់ចំណូលទាំងអស់* និង*ភាពញឹកញាប់*ដែលមនុស្សម្នាក់ៗបានទទួលប្រាក់ចំណូល ។ សូមដាក់ភ្ជាប់ព័ត៌មានបន្ថែម បើសិនជាចាំបាច់ ។ រំលងចំណុចទី ៣ ខាងក្រោម លុះត្រាតែក្មេងៗទាំងអស់ដែលកំពុងតែដាក់ពាក្យសុំអត្ថប្រយោជន៍អាហារឥតគិតថ្លៃ នៅក្នុងចំណុចទី២ ដែលមានលេខសំណុំរឿង ឬបើការដាក់ពាក្យសុំនេះគឺសំរាប់កូនចិញ្ចឹម។ ទំរកការណែនាំបង្ហាញប្រាក់ចំណូលខ្ពស់ ដើម្បីអាចអោយមានសិទ្ធិទទួលអត្ថប្រយោជន៍អាហារសាលា។

| **ឈ្មោះ *មនុស្សពេញវ័យទាំងអស់* ក្នុងក្រុមគ្រួសារ (សមាជិកក្រុមគ្រួសារទាំងអស់ដែលមិននៅក្នុងបញ្ជីរាយនាមផ្នែកទី១)** នាមខ្លួន | នាមត្រកូល | គូសគំនូសនៅលើខ្ទង់នេះ ប្រសិនបើ មនុស្សណាម្នាក់គ្មានប្រាក់ចំណូល√ | **ប្រាក់ចំណូល** សរសេរប្រាក់ចំណូល *និង*ភាពញឹកញាប់ដែលមនុស្សម្នាក់ៗបានទទួល : **weekly**, **bi-weekly** (ពីរអាទិត្យម្តង), **twice per month**, **monthly**, ឬ **yearly** ។ ប្រសិនបើប្រាក់ចំណូលប្រែប្រួល សូមសរសេរចូលនូវប្រាក់ចំណូល ដែលបានទទួលធម្មតា ។<br>ប្រាក់ថ្លៃឈ្នួលធ្វើការ និងប្រាក់ខែ *រួមមុនកាត់ពន្ធ* ពីការងារ-មុនដកប្រាក់ផ្សេងៗរួចហើយ | ប្រាក់រ៉ឺត្រែត, SSI, ប្រាក់ចូលនិវត្តន៍, ប្រាក់សុខសន្តិសុខសង្គម | ប្រាក់ជំនួយសាធារណៈ, ប្រាក់ឧបត្ថម្ភកូន, ប្រាក់ឧបត្ថម្ភប្រពន្ធប្តី | ប្រាក់អត់ការងារ, ប្រាក់សងថ្លៃឲ្យ កម្មករ, ប្រាក់ធ្វើកូនដកម្ម | ប្រាក់ចំណូលផ្សេងៗទៀត រួមទាំងបានមកពីស្រែចំការ/មុខរបរខ្លួនឯង *បានទូទាត់រួច* |
|---|---|---|---|---|---|---|---|
| 1 | | | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ_______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ |
| 2 | | | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ_______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ |
| 3 | | | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ_______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ |
| 4 | | | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ_______ | $_______ក្នុងមួយ _______ | $_______ក្នុងមួយ _______ |

**4** ប្រសិនបើកូនរបស់អ្នកត្រូវបានគេយល់ព្រមអោយអត្ថប្រយោជន៍សាលានោះ, ព័ត៌មាននេះអាចចែកចាយជាមួយនឹងមីនីសូតាខែរ (MinnesotaCare) និងការធានារ៉ាប់រងពេទ្យទូទៅ (General Assistance Medical Care) ដើម្បីសំគាល់កូនក្មេងដែលអាចទទួលបាននូវការធានារ៉ាប់ពេទ្យ។ សូមមើលទំព័រខាងក្រោយសំរាប់ព័ត៌មានបន្ថែម។ ទុកឲ្យប្រអប់ នៅទំនេរ ដើម្បីបណ្តោយឲ្យមានការប្តូរព័ត៌មាន។

☐ សូមកុំចែកចាយព័ត៌មានជាមួយកម្មវិធីធានារ៉ាប់រងសុខភាព មីនីសូតាខែរ។ ☐ សូមកុំចែកចាយព័ត៌មានជាមួយនិងការធានារ៉ាប់រងពេទ្យទូទៅ។

**5** ខ្ញុំសូមបញ្ជាក់ថា ព័ត៌មានដែលបានផ្តល់ឲ្យនេះគឺពិតប្រាកដ ហើយត្រឹមត្រូវ ។ ដោយសារតែថវិកាពីរដ្ឋបាលសហព័ន្ធ និងរដ្ឋ អាចនឹងបានបង់ឲ្យដោយសំអាងលើព័ត៌មាននេះ នោះខ្ញុំយល់ថា អ្នកមុខអ្នកការសាលារៀន និងអ្នករដ្ឋការរដ្ឋ អាចបញ្ជាក់ព័ត៌មាននេះឲ្យបានច្បាស់លាស់ ហើយថា បើខ្ញុំបានជំរាបដោយគ្មានភាពត្រឹមត្រូវ ដោយមានចេតនា ខ្ញុំអាចនឹងត្រូវបានជាប់ទោសពិន័យ តាមច្បាប់ជាធរមាន ។

នៃសមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ (បានដំរូវ) ______________________ សរសេរឈ្មោះជាអក្សរពុម្ព : ______________________ ខែថ្ងៃឆ្នាំ : ______________

លេខសូស្យាល់សឹគ្យូរិទី (បានដំរូវ បើផ្នែកទី 3 បានបំពេញចប់) : ___ ___ ___-___ ___-___ ___ ___ ___ ☐ ឬខ្ញុំឥតមានលេខសូស្យាល់សឹគ្យូរិទីទេ

អាសយដ្ឋាន : ______________________ ទីក្រុង ____________ ស៊ីបកូដ __________ ទូរស័ព្ទផ្ទះ ___________ ទូរស័ព្ទធ្វើការ ___________

**សំរាប់តែការិយាល័យប្រើ**

Total Household Size: ____ Total Household Income: ________
Or Household Receives: MFIP / Food Stamps / FDPIR
Approved: Free ____ Reduced-Price ____ Temporary until _____, _____, _____
Denied: Incomplete ____ Income Too High ____ Other:
Signature of Determining Official: ________________________ Date:________
Withdrawn:_________
Change Status To: _____________________ Reason:

**សំរាប់តែការិយាល័យប្រើ**

Date Verification Sent: ______________ Response Due: ______________ 2nd Notice Sent: _________________
Result: No Change ___ Free to Reduced-Price ___ Free to Paid ___ Reduced-Price to Free ___ Reduced-Price to Paid ___
Reason for Change: Income___ Household Size ___ Change in Benefits ___ Refused Cooperation ___ Other:
Date 'Notice of Change' Sent: ____________
Signature of Verifying Official: ______________________________________________________ Date: _____________

## លេខសូស្យាល់សឹគួរិទី (Social Security Number) /ការដាក់ពាក្យសុំដោយចប់សព្វគ្រប់

ក្រឹត្យម្ហូបអាហារថ្ងៃត្រង់នៅសាលារៀននៃប្រជាជាតិ គឺជំរូវថា លុះត្រាណាតែបានផ្តល់លេខជំនួយ MFIP, អាហាររូបិយប័ណ្ណ, ឬអត្ថប្រយោជន៍ FDPIR សំរាប់កូនរបស់អ្នក ឬរូបអ្នកដែលកំពុងតែដាក់ពាក្យសុំសំរាប់កូនចិញ្ចឹម ម្ល៉ោះហើយសមាជិកក្នុងក្រុមគ្រួសារដែលបានចុះហត្ថលេខាលើលិខិតដាក់ពាក្យសុំ ត្រូវតែផ្តល់លេខសូស្យាល់សឹគួរិទីរបស់គាត់ ឬត្រូវបញ្ជាក់ថាគាត់ឥតមានលេខសូស្យាល់សឹគួរិទីទេ ។ នៅក្នុងខដែលមានចែង លេខសូស្យាល់សឹគួរិទីគឺមិនជាចាំបាច់ឡើយ ក៏ប៉ុន្តែបើលេខសូស្យាល់សឹគួរិទីមិនបានផ្តល់ឲ្យទេ ឬបើសិនពុំមានការបញ្ជាក់ថាអ្នកចុះហត្ថលេខាឥតមានលេខសូស្យាល់សឹគួរិទីទេ ការដាក់ពាក្យសុំមិនអាចទទួលយល់ព្រមបានឡើយ ។

ដើម្បីបំពេញឲ្យសព្វគ្រប់ នោះការដាក់ពាក្យសុំដែលអាស្រ័យលើជំនួយសាធារណៈ ត្រូវតែមានរាប់ទាំងឈ្មោះរបស់ក្មេង លេខជំនួយ និងហត្ថលេខានៃសមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ ។ ការដាក់ពាក្យសុំដែលចប់សព្វគ្រប់ ដោយអាស្រ័យទៅលើប្រាក់ចំណូលក្នុងក្រុមគ្រួសារ ត្រូវតែមានរាប់នូវឈ្មោះសមាជិកទាំងអស់ក្នុងក្រុមគ្រួសារ ចំនួនប្រាក់ចំណូលដែលសមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យបានទទួល ហត្ថលេខានៃមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ និងលេខសូស្យាល់សឹគួរិទីរបស់សមាជិកក្រុមគ្រួសារ ដែលបំពេញលិខិតដាក់ពាក្យសុំ ។ ការដាក់ពាក្យសុំដែលចប់សព្វគ្រប់សំរាប់កូនចិញ្ចឹម ត្រូវតែមានរាប់បញ្ចូលនូវឈ្មោះក្មេង ចំនួនប្រាក់ចំណូលបានទទួលសំរាប់ក្មេងនោះចាយវាយផ្ទាល់ខ្លួន និងហត្ថលេខានៃសមាជិកក្រុមគ្រួសារជាមនុស្សពេញវ័យ ។

### ការពិនិត្យបញ្ជាក់

សាលារៀន ទាំងក្រសួងសិក្សាធិការរដ្ឋមីនេសូតា អាចប្រើព័ត៌មានដែលបានផ្តល់ឲ្យនៅលើលិខិតបំពេញនេះ ដើម្បីប្រឹងប្រែងបញ្ជាក់ពីភាពត្រឹមត្រូវនៃទំហំគ្រួសារ និងប្រាក់ចំណូលក្នុងក្រុមគ្រួសារ ហើយក៏ដើម្បីបញ្ជាក់ព័ត៌មានជំនួយសាធារណៈដែលបានថ្លែងលើលិខិតដាក់ពាក្យសុំ ។ ការប្រឹងប្រែងបញ្ជាក់ទាំងនេះ អាចធ្វើទៅតាមរយៈកម្មវិធីពិនិត្យសាជាថ្មី ការជំរះបញ្ជីប្រាក់ និងការស៊ើបសង្កេត ព្រមទាំងអាចទាក់ទងជាមួយនឹងភ្នាក់ងាររដ្ឋនានា ដូចជាក្រសួងសន្តិសុខសេដ្ឋកិច្ចរដ្ឋមីនេសូតា ឬក្រសួងកិច្ចការមនុស្សជាតិ និងក្រសួងប្រាក់ចំណូល ដើម្បីបញ្ជាក់ពីប្រាក់ចំណូល ឬការយល់ព្រមនៅពេលបច្ចុប្បន្នសំរាប់ជំនួយសាធារណៈ ។ ការប្រឹងប្រែងទាំងនេះអាចបណ្តាលឲ្យមានការបាត់បង់ ឬការកាត់បន្ថយអត្ថប្រយោជន៍ ឬការទាមទារខាងការចាត់ចែង ឬក៏ចាត់វិធានការតាមច្បាប់ បើសិនជាអ្នករាយការណ៍ព័ត៌មានមិនត្រឹមត្រូវទេ ។ ព័ត៌មានដែលអ្នកផ្តល់ឲ្យនៅលើលិខិតបំពេញនេះ នឹងមិនបានបញ្ចេញទៅឲ្យអ្នកណាម្នាក់ សំរាប់គោលបំណងផ្សេងៗទៀតឡើយ លុះត្រាណាតែមាតាបិតា ឬអ្នកអាណាព្យាបាលសរសេរសំបុត្រស្នើសុំឲ្យបញ្ចេញ ។

### ភាពឯកជននៃព័ត៌មាន ដែលអ្នកផ្តល់ឲ្យនៅលើលិខិតបំពេញនេះ /ការបញ្ជាក់

ព័ត៌មានដែលអ្នកផ្តល់ឲ្យនៅលើលិខិតបំពេញនេះ គឺជាទិន្នន័យឯកជន(លាក់ការពក៏) ។ ព័ត៌មានគឺបានប្រើសំរាប់អនុម័ត និងបញ្ជាក់ថាតើក្មេងៗនៅក្នុងក្រុមគ្រួសាររបស់អ្នក មានគុណសម្បត្តិទទួលម្ហូបអាហារដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ នៅសាលារៀនដែរឬអត់ ហើយសំរាប់ការគ្រប់គ្រងនិងប្រតិបត្តិកម្មវិធីអាហារពេលព្រឹកនិងថ្ងៃត្រង់។ យើងអាចចែកចាយពត៌មាននឹងផ្នែកការសិក្សា, ផ្នែកសុខភាព, និងកម្មម្ហូបអាហារ ដើម្បីជួយពួកគេលៃ, ផ្តល់លុយ, និងអនុមត្តិអត្ថប្រយោជន៍សំរាប់កម្មវិធីរបស់ខ្លួន; និងសំរាប់ទគបាលជួយពួកគេក្នុងការប្រព្រឹត្តបទល្មើសវិន័យរបស់គេ។ ព័ត៌មានដែលអ្នកផ្តល់នៅលើលិខិតដាក់ពាក្យសុំនេះ គឺមិនបញ្ចេញទៅអ្នកណាម្នាក់ សំរាប់គោលបំណងផ្សេងៗទៀតឡើយ លុះត្រាតែមាតាបិតា ឬអ្នកអាណាព្យាបាលសរសេរសំបុត្រស្នើសុំឲ្យបញ្ចេញ ។

### ភាពឯកជននៃលក្ខណៈសិទ្ធិទទួល សំរាប់កូនរបស់អ្នក

លក្ខណៈសិទ្ធិទទួលនៃកូនរបស់អ្នក (សិទ្ធិទទួលម្ហូបអាហារនៅសាលា ដោយ “ឥតគិតថ្លៃ” ឬ “បញ្ចុះថ្លៃ” ឬ “បង់ថ្លៃ”) ក៏ជាទិន្នន័យឯកជន ដែលបានប្រើដោយសាលារៀន ដើម្បីផ្តល់អត្ថប្រយោជន៍(ជំនួយ)ម្ហូបអាហារនៅសាលារៀនដ៏ត្រឹមត្រូវសំរាប់ក្មេង ។ នៅសាលាសាធារណៈក្នុងមណ្ឌលលក្ខណៈសិទ្ធិទទួលរបស់ក្មេងនិមួយៗ គឺត្រូវបានកត់ទុកនៅក្នុងប្រព័ន្ធកំព្យូទ័រពាសពេញរដ្ឋ ដែលប្រើសំរាប់រាយការណ៍ទិន្នន័យសិស្សទៅក្រសួងសិក្សាធិការរដ្ឋមីនេសូតា តាមច្បាប់រដ្ឋបានជំរូវ ។ ក្រសួងសិក្សាធិការរដ្ឋមីនេសូតា ប្រើព័ត៌មាននេះដើម្បី (1) ចាត់ចែងកម្មវិធីរដ្ឋ និងកម្មវិធីរដ្ឋបាលសហព័ន្ធ (2) គិតគូរពីថវិកាសំរាប់បង់ឲ្យសាលាសាធារណៈ ហើយ (3) វិនិច្ឆ័យពីគុណភាពនៃកម្មវិធីការអប់រំរបស់រដ្ឋ ។

ច្បាប់រដ្ឋបាលសហព័ន្ធអនុញ្ញាតឲ្យសាលារៀនបញ្ចេញលក្ខណៈសិទ្ធិទទួល ទៅឲ្យអ្នកមុខអ្នកការនៃកម្មវិធីប្រភេទផ្សេងៗដូចតទៅ ដោយពុំបាច់មានសេចក្តីយល់ព្រមពីក្រុមគ្រួសារឡើយ (1) កម្មវិធីការអប់រំរដ្ឋបាលសហព័ន្ធ (2) កម្មវិធីការអប់រំ ឬសុខភាពរដ្ឋ ដែលចាត់ចែងដោយសាលា ឬដោយភ្នាក់ងាររដ្ឋ ហើយ (3) កម្មវិធីអាហារមានជីវៈជាតិរដ្ឋបាលសហព័ន្ធ រដ្ឋ ឬក្នុងតំបន់ ដែលជំរូវឲ្យមានការចូលរួមស្រដៀងគ្នានឹងកម្មវិធីម្ហូបអាហារថ្ងៃត្រង់នៅសាលារៀននៃប្រជាជាតិ ។ អ្នកមុខអ្នកការសាលារៀន អាចធ្វើព័ត៌មានស្តីអំពីកម្មវិធីផ្សេងៗទៀត ឬអត្ថប្រយោជន៍ដែលអាចជាការល្អសំរាប់ក្រុមគ្រួសារដែលមានគុណសម្បត្តិទទួលម្ហូបអាហារនៅសាលារៀន ដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ ។ ព័ត៌មានស្តីពីសិទ្ធិទទួលម្ហូបអាហារនៅសាលារៀន ក៏ប្រើសំរាប់របាយការណ៍ស្ថិតិ ដោយឥតមានសំគាល់ភិនភាគបុគ្គលណាម្នាក់ឡើយ ។ ពត៌មានការទទួលរបស់កុមារម្នាក់ មិនត្រូវបានចែកចាយ សំរាប់គោលការណ៍ណាមួយឡើយ លើកលែងតែមានសំណូមពីឪពុកម្តាយ ឬអានាព្យាបាល ជាលាយល័ក្ខអក្សរ។

### ការចែកចាយពត៌មានជាមួយនឹងការធានារ៉ាប់រងមីនីសូតា និងកម្មវិធីការ និង ការធានារ៉ាប់រងពេទ្យទូទៅ

កូមក្មេងដែលអាចទទួលអាហារសាលាដោយឥតគឹតថ្លៃ និងបញ្ចុះតម្លៃ។ ក្មេងនោះអាចទទួលកម្មវិធីធានារ៉ាប់រងសុខភាពមីនីសូតាបាន។ ឈ្មោះរបស់កូនលោកអ្នក សំរាប់អាហារសាលា (អាចទទួល អាហារឥតគឹតថ្លៃ ឬបញ្ចុះតម្លៃ) អាចចែកចាយជាមួយនឹងមីនីសូតាឃៀ និង និងការធានារ៉ាប់រងពេទ្យទូទៅ លើកលែងតែមិនអនុញ្ញាត។ គេមិនតម្រូវអោយលោកអ្នកចែកចាយពត៌មាន សំរាប់គោលបំណងនេះទេ ហើយការសំរេចរបស់អ្នក នឹងមិនប៉ះពាល់ដល់ការយល់ព្រមសំរាប់អត្ថប្រយោជន៍អាហារសាលាទេ។

**ការស្ទង់មតិសិទ្ធិស៊ីវិល** (តាមការស្ម័គ្រចិត្ត)

**1. ជាតិពន្ធ** (គូសមួយ) :

☐ **ហ៊ិស្ប៉ានិក ឬឡាទីណូ** ☐ **មិនមែនជាហ៊ិស្ប៉ានិក ឬឡាទីណូ**

**2. សាសន៍** (គូសមួយ ឬលើសពីមួយ) :

☐ **អាមេរិកាំងឥណ្ឌៀន ឬជនជាតិដើមអាឡាស្កា**

☐ **អាស៊ី**

☐ **អាមេរិកាំង-អាហ្រ្វិក ឬស្បែកខ្មៅ**

☐ **ជនជាតិដើមហាវ៉ៃ ឬអ្នកកោះប៉ាស៊ីហ្វិកផ្សេងទៀត**

☐ **ស្បែកស**

*ដោយស្របទៅតាមច្បាប់រដ្ឋបាលសហព័ន្ធ និងក្រឹត្យនៃក្រសួងកសិកម្មសហរដ្ឋអាមេរិក ស្ថាប័ននេះត្រូវបានហាមឃាត់ មិនឲ្យមានការរើសអើង ដោយយោងទៅលើជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ភេទ អាយុ ឬភាពពិការ សោះឡើយ ។ ដើម្បីធ្វើពាក្យប្តឹងអំពីការរើសអើង សូមសរសេរ សំបុត្រផ្ញើទៅ USDA, Director, Office of Civil Rights, 1400 Independence Avenue, SW, Washington, D.C. 20250-9410 ឬទូរស័ព្ទទៅលេខ (800) 795-3272 ឬ (202) 720-6382 (TTY) ។ USDA គឺជាអ្នកផ្តល់ និងជានិយោជក ស្មើឱកាសគ្នា ។*